ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :.......១៥៥/២០...........ក.ប/ស.ណ.ន.ខ.ល

**សេចក្តីណែនាំបន្ថែម**

**ស្តីពី**

**វិធានការបង្ការជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស**

ដើម្បីចូលរួមចំណែកបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស, កម្មករនិយោជិត, ម្ចាស់ ឬអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករ, មន្ត្រីអធិការកិច្ចការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្មារតីនៃសេចក្តីណែនាំលេខ០០៤/២០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការបង្ការជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមសេចក្តីណែនាំនានារបស់ក្រសួងសុខាភិបាល ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសត្រូវៈ

**សម្រាប់ម្ចាស់ ឬនាយករោងចក្រ សហគ្រាសៈ**

១. មិនត្រូវអនុញ្ញាតឱ្យបុគ្គលណាម្នាក់ដែលមិនមែនជាអ្នកគ្រប់គ្រង ឬកម្មករនិយោជិត ឬមន្ត្រីមានសមត្ថកិច្ច ជាពិសេសបុគ្គលដែលមានប្រវត្តិនៃការធ្វើដំណើរ និងស្នាក់នៅមិនច្បាស់លាស់ ចេញចូលបរិវេណរោងចក្រ សហគ្រាស ជាពិសេសក្នុងបរិវេណផលិតកម្មជាដាច់ខាត។

២. ត្រូវភ្ជាប់ឱ្យបាននូវប្រវត្តិនៃការធ្វើចត្តាឡីស័ក ការស្នាក់នៅ និងស្ថានភាពសុខភាពរបស់ភ្ញៀវបរទេស ដែលត្រូវមកធ្វើទស្សនកិច្ចនៅរោងចក្រ សហគ្រាស ដោយត្រូវកត់ឈ្មោះ លេខទូរសព្ទ និងអាសយដ្ឋានស្នាក់នៅរបស់ភ្ញៀវទាំងនោះ ហើយរក្សាទុកឱ្យបានល្អ។

៣. ត្រូវស្នើសុំ និងតម្រូវឱ្យភ្ញៀវ និងមន្ត្រីមានសមត្ថកិច្ច លាងដៃនឹងទឹកអាល់កុល ឬជែល ឬសាប៊ូ វាស់កម្តៅ និងពាក់ម៉ាស់ មុននឹងអនុញ្ញាតឱ្យចូលក្នុងបរិវេណរោងចក្រ សហគ្រាស។ សម្រាប់មន្ត្រីក្រសួងដែលមិនអនុវត្តតាមវិធានការនេះ សូមផ្តល់ដំណឹងមកក្រសួងតាមរយៈ Telegram លេខ ០១២ ៨៦៨ ៦៩៩ ឬ ០១២ ៨៧២ ១៦១ ឬ ០១៧ ៩៨៧ ២៦១ ដើម្បីក្រសួងដាក់ទណ្ឌកម្មលើមន្ត្រីនោះ។

៤. ត្រូវចាត់តាំងអ្នកគ្រប់គ្រងចំនួន ២នាក់ ឬបុគ្គលិក ១ក្រុម ឱ្យទទួលខុសត្រូវលើការងារផ្សព្វផ្សាយ និងត្រួតពិនិត្យវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ជាពិសេសត្រូវធ្វើបញ្ជីត្រួតពិនិត្យជាប្រចាំថ្ងៃ ដើម្បីតាមដានសកម្មភាពអនុវត្តជាក់ស្តែងនៅតាមច្រកចេញចូលរបស់រោងចក្រ សហគ្រាសរបស់ខ្លួន។ រោងចក្រ សហគ្រាស ត្រូវរក្សាទុកបញ្ជីត្រួតពិនិត្យដែលជាកម្មវត្ថុថ្មីនៃការធ្វើអធិការកិច្ចការងារនេះឱ្យបានត្រឹមត្រូវ។

៥. ត្រូវវាស់កម្តៅគ្រប់កម្មករនិយោជិតទាំងអស់ មុននឹងអនុញ្ញាតឱ្យចូលក្នុងបរិវេណរោងចក្រ សហគ្រាស និងត្រូវផ្តល់ទឹកអាល់កុល ឬជែលលាងដៃ ឬសាប៊ូលាងដៃ នៅមាត់ច្រកចេញចូលអគារផលិតកម្ម សម្រាប់កម្មករនិយោជិតលាងសម្អាតដៃមុនពេលចូលធ្វើការ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៥

៦. ត្រូវស្វែងរក និងផ្តល់ទីតាំងដែលកម្មករនិយោជិតងាយមើលឃើញ ព្រមទាំងពិនិត្យលទ្ធភាពរៀបចំឧបករណ៍បំពងសម្លេង សម្រាប់ធ្វើការបិទផ្សាយផ្ទាំងព័ត៌មាន ឬចាក់ផ្សាយសារសម្លេងនានាពាក់ព័ន្ធនឹងវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដែលផលិតដោយក្រសួងសុខាភិបាល។

៧. ត្រូវពិភាក្សាជាមួយប្រតិភូបុគ្គលិក និងអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករ ដើម្បីបង្កើតជាសម្លេងរួមមួយតម្រូវឱ្យម្ចាស់យានយន្តដឹកជញ្ជូនកម្មករត្រូវលាងសម្អាត និងបាញ់អាល់កុលសម្លាប់មេរោគយានយន្តរបស់ខ្លួននៅរាល់មុនពេល និងក្រោយពេលដឹកជញ្ជូនកម្មករ។

៨. ត្រូវផ្តល់ឈ្មោះ លេខទូរសព្ទ និងទីតាំងមួយច្បាស់លាស់ដល់កម្មករនិយោជិត ដើម្បីរាយការណ៍ និងជូនដំណឹងអំពីករណីសង្ស័យ ឬកម្មករនិយោជិតណាម្នាក់មានកម្តៅលើសពី ៣៧,៥អង្សា និងមានរោគសញ្ញាមួយយ៉ាងតិចដូចជា ក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី ឬពិបាកដកដង្ហើម និងមានប្រវត្តិធ្វើដំណើរទៅតំបន់ដែលមានករណីវីរុសមានកូវីដ-១៩ ឬបានប៉ះពាល់ជាមួយអ្នកមានវីរុសមានកូវីដ-១៩ ឬអ្នកស្លាប់ដោយសារជំងឺស្រួចស្រាវដោយមិនដឹងពីមូលហេតុច្បាស់លាស់ក្នុងអំឡុងពេល ១៤ថ្ងៃ មុនចេញរោគសញ្ញា។

៩. ត្រូវបម្រុងទុកម៉ាស់ឱ្យបានគ្រប់គ្រាន់ សម្រាប់បើកផ្តល់ដល់កម្មករនិយោជិត តាមវេជ្ជបញ្ជារបស់ពេទ្យ អាស្រ័យលើស្ថានភាពសុខភាព និងស្ថានភាពទូទៅរបស់កម្មករនិយោជិតម្នាក់ៗ។

១០. ត្រូវផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ ដល់កម្មករនិយោជិត និងដាស់តឿនកម្មករនិយោជិតឱ្យហូបអាហារដែលផ្តល់នូវជីវជាតិល្អ សម្រាកឱ្យបានគ្រប់គ្រាន់ ព្រមទាំងកុំធ្វើដំណើរទៅកាន់តំបន់ណា ដែលមានករណីវីរុសមានកូវីដ-១៩ ជាពិសេសជៀសវាងជាដាច់ខាតការប៉ះពាល់ផ្ទាល់ជាមួយអ្នកកើតជំងឺកូវីដ-១៩។

១១. ត្រូវបន្ត និងលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈល្អជាមួយកម្មករនិយោជិត និងត្រូវរួមគ្នាពិភាក្សាប្រកបដោយភាពស្មោះត្រង់ក្នុងការដោះស្រាយបញ្ហា ឬចំណុចប្រឈមដែលកើតឡើងដោយឥទ្ធិពលជំងឺកូវីដ-១៩ ដើម្បីបង្កើនជំនឿទុកចិត្តគ្នាទៅវិញទៅមក និងរក្សាបាននូវអត្ថប្រយោជន៍រួមរបស់រោងចក្រ សហគ្រាស និងកម្មករនិយោជិត។

**សម្រាប់កម្មករនិយោជិតត្រូវ៖**

១. ចូលរួមសហការ និងអនុវត្តតាមវិធានការនានាពាក់ព័ន្ធនឹងវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដែលចេញដោយក្រសួងសុខាភិបាល អាជ្ញាធរមានសមត្ថកិច្ច និងរោងចក្រ សហគ្រាសរបស់ខ្លួន។

២. ផ្តល់ព័ត៌មាន និងរាយការណ៍ ក៏ដូចជាលើកសំណូមពរជាបន្ទាន់ទៅអ្នកគ្រប់គ្រងរដ្ឋបាល ឬប្រធានផ្នែក ឬប្រធានក្រុម ឬបុគ្គលណាមួយ ដែលរោងចក្រ សហគ្រាសបានជូនដំណឹង ក្នុងករណីមានរោគសញ្ញាសង្ស័យណាមួយកើតឡើង ចំពោះខ្លួនឯង ឬអ្នកនៅក្បែរខាងរបស់ខ្លួន។

៣. ពាក់ម៉ាស់ជានិច្ច ប្រសិនជាតម្រូវដោយគ្រូពេទ្យ និងត្រូវពាក់ម៉ាស់ ឬក្រម៉ា ពេលជិះយានយន្តរួមគ្នា។

៤. រួមគ្នាតាមដាន និងតម្រូវឱ្យម្ចាស់យានយន្តដឹកជញ្ជូនកម្មករលាងសម្អាត និងបាញ់អាល់កុលសម្លាប់មេរោគយានយន្តរបស់ខ្លួននៅរាល់មុនពេល និងក្រោយពេលដឹកជញ្ជូនកម្មករ។

៥. ខិតខំរក្សាទំនាក់ទំនងវិជ្ជាជីវៈល្អជាមួយតំណាងនិយោជក និងប្រតិភូបុគ្គលិក ព្រមទាំងចូលរួមដោះស្រាយចំណុចប្រឈមនានានៅក្នុងរោងចក្រ សហគ្រាស ប្រកបដោយស្មារតីសហការ និងយោគយល់គ្នា។

៦. ស្តាប់ប្រភពព័ត៌មានឱ្យបានច្បាស់លាស់ ជៀសវាងជឿតាមពាក្យចចាមអារ៉ាម ដែលបង្កើតជាភាពចលាចល និងខូចខាតប្រយោជន៍។ មានតែប្រភពព័ត៌មាន ឬសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលតែមួយគត់ ដែលជាប្រភពព័ត៌មានពិតប្រាកដ និងអាចជឿទុកចិត្តបាន។

**សម្រាប់ម្ចាស់ ឬអ្នកផ្ដល់សេវាដឹកជញ្ជូនកម្មករត្រូវ៖**

១. រួមចំណែកក្នុងការទទួលខុសត្រូវចំពោះមុខសង្គម និងសហគមន៍របស់ខ្លួន ជាពិសេសចំពោះមុខបងប្អូនកម្មករ ដែលជាកូនក្មួយរស់នៅក្នុងភូមិឃុំជាមួយគ្នា ដែលនេះគឺជាស្មារតីមនុស្សធម៌ផង គុណធម៌ផង និងសាសនាផង។

២. លាងសម្អាត និងបាញ់អាល់កុលសម្លាប់មេរោគយានយន្តនៅរាល់មុនពេល និងក្រោយពេលដឹកជញ្ជូនកម្មករ។

៣. ណែនាំអ្នកបើកបរយានយន្តឱ្យបើកបរដោយប្រុងប្រយ័ត្ន និងមិនត្រូវធ្វើដំណើរទៅទីកន្លែងណាមួយដែលមានផ្ទុះករណីវិជ្ជមានកូវីដ-១៩។

**សម្រាប់មន្ត្រីអធិការកិច្ចការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារត្រូវ៖**

១. ពាក់ម៉ាស់ជានិច្ចក្នុងពេលបំពេញភារកិច្ច ជាពិសេសពេលចុះធ្វើអធិការកិច្ចការងារ ឬផ្សះផ្សាវិវាទការងារនៅតាមទីតាំងរោងចក្រ សហគ្រាសណាមួយ។

២. អនុវត្តតាមការណែនាំ និងសំណូមពរនានាពាក់ព័ន្ធនឹងវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ នៅពេលចុះបំពេញការងារនៅតាមរោងចក្រ សហគ្រាស ដូចជា ត្រូវពាក់ម៉ាស់ លាងសម្អាតដៃ និងឆ្លងកាត់ការវាស់កម្ដៅមុននឹងចូលក្នុងបរិវេណរោងចក្រ សហគ្រាស ឬអគារផលិតកម្ម។ មន្ត្រីដែលមិនអនុវត្តតាមការណែនាំ និងសំណូមពរនេះ អាចត្រូវរងការដាក់ទណ្ឌកម្ម ក្នុងករណីដែលរោងចក្រ សហគ្រាសផ្ដល់ព័ត៌មាន និងភស្តុតាងច្បាស់លាស់។

៣. ត្រៀមសហការជាមួយរោងចក្រ សហគ្រាស និងភាគីពាក់ព័ន្ធ ដើម្បីចុះអប់រំ ផ្សព្វផ្សាយ និងណែនាំអំពីរោគសញ្ញានៃជំងឺកូវីដ-១៩ ក៏ដូចជាវិធានការ និងសេចក្ដីណែនាំនានាពាក់ព័ន្ធនឹងការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដើម្បីបង្កើនភាពជឿជាក់ និងច្បាស់លាស់របស់កម្មករនិយោជិត។

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស, កម្មករនិយោជិត, ម្ចាស់ ឬអ្នកផ្ដល់សេវាដឹកជញ្ជូនកម្មករ, មន្ត្រីអធិការកិច្ចការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារនឹងអនុវត្តតាមខ្លឹមសារសេចក្ដីណែនាំឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ២រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:

- ក្រសួងសុខាភិបាល
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត

  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពក្រោមឱវាទ
- គ្រប់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានី ខេត្ត

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ